មេធាវីនាំមុខតំណាងដើម
បណ្តឹងរដ្ឋប្បវេណី
Civil Party Lead Co-Lawyers' Section
Section des co-avocats principaux
des parties civiles

**លិខិត**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Jun-2014, 15:33
CMS/CFO: Sann Rada

**ជម្រាបជូន:** ចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង

**ពី:** សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

**ចម្លងជូន:** Ken ROBERTS, មន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** **ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងឯកសារ E305/7/1 "សេចក្តីណែនាំឱ្យសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីផ្តល់ព័ត៌មានបន្ថែមទាក់ទិននឹងការស្នើសុំវិធានការការពារ"**

១. កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ និងដោយមានការបញ្ជាក់ពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដែលមានលិខិតទទួលសិទ្ធិតំណាងផ្លូវច្បាប់ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានកំណត់អត្តសញ្ញាណដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ (TCCP-19) ដែលបានស្នើសុំវិធានការការពារ ហើយបានដាក់ជូនអង្គជំនុំជម្រះ ជាមួយឧបសម្ព័ន្ធដាច់ដោយឡែក និងសម្ងាត់បំផុត[1]។ ក៏ប៉ុន្តែបន្ទាប់ពីបានប្រឹក្សាយោបល់បន្ថែមជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង ថាវាមិនមានភាពចាំបាច់ទេក្នុងការបន្តស្នើសុំវិធានការការពារ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងខាងលើ ពីព្រោះគាត់គ្មានការភ័យខ្លាចពីសុវត្ថិភាពរបស់គាត់ទៀតទេ។

[1] ឧបសម្ព័ន្ធ II - បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលបានធ្វើបច្ចុប្បន្នភាព(សម្រាប់អ្នកដែលស្នើសុំនូវវិធានការការពារ)/ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឯកសារលេខ **E305/7.1.2**, ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤

២. ដូច្នេះ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសូមដាក់ជូនសំណើនេះ ដើម្បីលុបចោលនូវសំណើសុំវិធានការការពារសម្រាប់ដើមបណ្តឹរដ្ឋប្បវេណីដែលមានលេខ TCCP-19 នៅក្នុងសំណុំរឿង ០០២/០២។

រាជធានី ភ្នំពេញ, ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៤



**ពេជ អង្គ**
សហមេធាវីជាតិនាំមុខ



**Marie GUIRAUD**
សហមេធាវីអន្តរជាតិនាំមុខ